**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ៧៦១/២៣ ក.ស.ភ.

ថ្ងៃចន្ទ ១៣រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង

## ស្តីពីការងារសាងសង់ប្រព័ន្ធលូរំដោះទឹក ប្រវែង ៦៧៥ម៉ែត្រ ពីច្រកទ្វារទី២ ភ្ជាប់ទៅផ្លូវរហាត់ខ្យល់ ស្ថិតនៅចំណតផែកុងតឺន័រLM១៧

កំពង់ផែស្វយ័តភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា កំពង់ផែស្វយ័តភ្នំពេញ នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការ លើការងារសាងសង់ប្រព័ន្ធលូរំដោះទឹក ប្រវែង ៦៧៥ម៉ែត្រ ពីច្រកទ្វារទី២ ភ្ជាប់ទៅផ្លូវរហាត់ខ្យល់ ស្ថិតនៅចំណតផែកុងតឺន័រLM១៧។

កំពង់ផែស្វយ័តភ្នំពេញ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បី និងចូលរួម ដេញថ្លៃ។ ឯកសារដេញថ្លៃមានដាក់លក់ នៅអង្គភាពលទ្ធកម្ម នៃកំពង់ផែស្វយ័តភ្នំពេញ ដែលមានអាសយដ្ឋាន អគារលេខ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញរាជធានីភ្នំពេញ ចាប់ពី**ថ្ងៃទី**១៤ **ខែ**សីហា **ឆ្នាំ២០២៣** តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០១០ ៤៤៤ ៦៤១)។

កាលបរិច្ឆេទឈប់ទទួលពាក្យសំណើដេញថ្លៃនៅម៉ោង១៤:៣០នាទី **ថ្ងៃទី**១៣ **ខែ**កញ្ញា **ឆ្នាំ២០២៣ ។**

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើវេលាម៉ោង១៤:៣០នាទី **ថ្ងៃទី**១៣ **ខែ**កញ្ញា **ឆ្នាំ២០២៣។**

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃ បានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយក**

**និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ហ៊ី-ប្ញាទី**

**ចម្លងជូន៖**

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-អង្គភាពប្រឆាំងអំពើពុករលួយ

-ឯកសារ-កាលប្បវត្តិ